ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី 25 ខែ មេសា ឆ្នាំ២០១៦។

ADB

# ធនាគារអភិវឌ្ឍន៍អាស៊ី

## ប្រទេសកម្ពុជា ៖ កម្មវិធីវិមជ្ឈការសេវាសាធារណៈ និងការអភិវឌ្ឍន៍វិស័យគ្រប់គ្រងហិរញ្ញវត្ថុ ដំណាក់កាលទី២ អនុកម្មវិធីទី១

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីវិមជ្ឈការសេវាសាធារណៈ និង ការអភិវឌ្ឍន៍វិស័យគ្រប់គ្រងហិរញ្ញវត្ថុដំណាក់កាលទី២ អនុកម្មវិធីទី១ |
| លេខគម្រោង | 49266-001 |
| ប្រទេស | កម្ពុជា |
| ស្ថានភាពគម្រោង | ស្នើ |
| ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ | កម្ចី |
| ប្រភពមូលនិធិ/ចំនួនទឹកប្រាក់ | **កម្ចី ៖ កម្មវិធីវិមជ្ឈការសេវាសាធារណៈ និង ការអភិវឌ្ឍន៍វិស័យគ្រប់គ្រងហិរញ្ញវត្ថុ ដំណាក់កាលទី២**<br>មូលនិធិអភិវឌ្ឍន៍អាស៊ី ៦០,០០ លានដុល្លារអាមេរិក |
| របៀបវារៈយុទ្ធសាស្ត្រ | កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន |
| កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ | អភិបាលកិច្ច និងការអភិវឌ្ឍន៍សមត្ថភាព<br>ដំណោះស្រាយផ្អែកចំណេះដឹង<br>ភាពជាដៃគូ |
| វិស័យ/អនុវិស័យ | **ការគ្រប់គ្រងវិស័យសាធារណៈ** ៖ វិមជ្ឈការ |
| សមធម៌យេនឌ័រ និង ការបញ្ជ្រាបយេនឌ័រ | ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព |

| | |
|---|---|
| ការពណ៌នា | |
| វិចារណភាពគម្រោង និងការតភ្ជាប់ទៅនឹងយុទ្ធសាស្រ្តប្រទេស/តំបន់ | |
| ផលប៉ះពាល់ | គោលបំណងរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយសមធម៌ ជូនប្រជាពលរដ្ឋតាមរយៈវិមជ្ឈការអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់ចែងនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)។ |
| លទ្ធផល | សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាមានភាពប្រសើរជាងមុន។ |
| ទិន្នផល | សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាបែបវិមជ្ឈការត្រូវបានពង្រឹង។<br>ប្រភពចំណូលគ្រប់គ្រាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញអាណត្តិការងាររបស់ពួកគេ ត្រូវបានផ្តល់ជូន។<br>ប្រព័ន្ធគណនេយ្យភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើង<br>ទិន្នផលគម្រោង។<br>ប្រព័ន្ធ និងស្ថាប័នសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើង។ |
| ទីតាំងភូមិសាស្រ្ត | |

## ប្រភេទនៃកិច្ចការពារ

| | |
|---|---|
| បរិស្ថាន | C |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | C |
| ជនជាតិដើមភាគតិច | B |

## សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម

| | |
|---|---|
| **ទិដ្ឋភាពផ្នែកបរិស្ថាន** | កម្មវិធីវិមជ្ឈការសេវាសាធារណៈ និង ការអភិវឌ្ឍន៍កម្រងវិស័យគ្រប់គ្រងហិរញ្ញវត្ថុ (DPSFM II) មានគោលបំណងជួយកែលម្អការផ្តល់សេវាសាធារណៈក្នុងមូលដ្ឋាន តាមរយៈការគាំទ្រដល់ការអភិវឌ្ឍន៍រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ពួកគេ ដោយអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) របស់រាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធី DPSFM ដំណាក់កាលទី២ ដែលបានស្នើឡើង នឹងរួមមានកម្ចីគោលនយោបាយមួយ និង កម្ចីគម្រោងមួយ។ កម្ចីគម្រោងនឹងផ្តល់ជំនួយបច្ចេកទេសសម្រាប់ការរចនា និង ការបង្កើតវិទ្យាស្ថានជាតិសម្រាប់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន។ នៅដំណាក់កាលនេះ ពុំមានសមាសធាតុការងារសំណង់ស៊ីវិលណាមួយ ត្រូវបានគេរំពឹងថានឹងត្រូវដាក់បញ្ចូលទៅក្នុងកម្ចីនេះឡើយ ដូច្នេះ គេមិនបានព្យាករណ៍ទៅលើផលប៉ះពាល់ផ្នែកបរិស្ថានណាមួយពីការអនុវត្តន៍គម្រោងនេះទេ។ |
| **ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត** (IR) | គម្រោងនេះ ពុំមានសមាសធាតុផ្នែកការងារសំណង់ស៊ីវិលឡើយ។ កម្ចីសម្រាប់គម្រោងនេះនឹងមានកម្រិតចំពោះតែការរៀបចំ និងការរចនាស្ថាប័ន ចំពោះវិទ្យាស្ថានជាតិ សម្រាប់រដ្ឋាភិបាលថ្នាក់មូលដ្ឋានប៉ុណ្ណោះ ដែលនេះគឺជាមូលដ្ឋានយុត្តិកម្មសម្រាប់ការចាត់ចំណាត់ថ្នាក់ប្រភេទ "C" សម្រាប់ IR។ ចំពោះកម្ចីដែលមានមូលដ្ឋានផ្អែកលើគោលនយោបាយវិញ ផលប៉ះពាល់នៃ IR ដោយផ្ទាល់ និងប្រយោល ដែលមានទំនាក់ទំនងទៅនឹងសកម្មភាពគោលនយោបាយ ដែលត្រូវទទួលបានការគាំទ្រពីកម្មវិធី នឹងត្រូវបានប៉ាន់ប្រមាណក្នុងលក្ខណៈជាផ្នែកមួយនៃ PPTA។ តារាងមួយនៃផលប៉ះពាល់ជាសក្តានុពលនៃកម្មភាពគោលនយោបាយនីមួយៗ រួមជាមួយនឹងវិធានការកាត់បន្ថយផលប៉ះពាល់សមស្រប នឹងត្រូវបានរៀបចំឡើង។ |
| **ជនជាតិដើមភាគតិច** | គម្រោងនេះ ពុំមានសមាសធាតុការងារសំណង់ស៊ីវិល ដែលអាចបង្កឱ្យមានផលប៉ះពាល់ទៅលើសហគមន៍/ក្រុមជនជាតិដើមភាគតិចឡើយ។ ចំពោះកម្ចីដែលមានមូលដ្ឋានផ្អែកលើគោលនយោបាយវិញ ផលប៉ះពាល់នៃ IR ដោយផ្ទាល់ និងប្រយោល ដែលមានទំនាក់ទំនងទៅនឹងសកម្មភាពគោលនយោបាយ ដែលត្រូវទទួលបានការគាំទ្រពីកម្មវិធី នឹងត្រូវបានប៉ាន់ប្រមាណក្នុងលក្ខណៈជាផ្នែកមួយនៃ PPTA។ តារាងមួយនៃផលប៉ះពាល់ជាសក្តានុពលនៃកម្មភាពគោលនយោបាយនីមួយៗ រួមជាមួយនឹងវិធានការកាត់បន្ថយផលប៉ះពាល់សមស្រប នឹងត្រូវបានរៀបចំឡើង។ បន្ថែមពីនេះទៀត ការរចនាយន្តការគណនេយ្យភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិសាកល្បងទាំង ១០ នឹងធានាបានថាក្រុមជនជាតិដើមភាគតិចនៅក្នុងស្រុកទាំងនេះ អាចមានលទ្ធភាពចូលរួមនៅក្នុងដំណើរការប្រកបដោយអត្ថន័យ។ |

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

| | |
|---|---|
| ក្នុងអំឡុងពេលនៃការរៀបចំគម្រោង | |
| ក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង | |

## បុគ្គលិកទទួលខុសត្រូវ

| | |
|---|---|
| មន្រ្តីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | Hiroyuki Aoki |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ (SERD) |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | ផ្នែកគ្រប់គ្រងវិស័យសាធារណៈ វិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម របស់ SERD |
| ទីភ្នាក់ងារប្រតិបត្តិ | **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**<br>ក្រសួងមហាផ្ទៃ<br>មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់<br>ខណ្ឌចំការមន រាជធានីភ្នំពេញ |

## កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | ០៣ កក្កដា ២០១៥ |
| បេសកកម្មស្វែងរកការពិត | ២១ មីនា ២០១៥ ទៅ ០៤ មេសា ២០១៥ |
| កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង (MRM) | ១៩ កញ្ញា ២០១៥ |
| ការអនុម័ត | ១៣ ធ្នូ ២០១៥ |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាព PDS លើកចុងក្រោយ | ១៧ កុម្ភៈ ២០១៦ |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី មិនផ្តល់ការធានា ឬ ភាពជាតំណាងណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។